អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣

# សេចក្តីប្រកាសព័ត៌មាន
# ប្រទេសជប៉ុនផ្តល់ថវិកា ២,៥លានដុល្លារសហរដ្ឋអាមេរិកជូន អ.វ.ត.ក

កាលពីថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣ ស្ថានទូតប្រទេសជប៉ុនប្រចាំទីក្រុងភ្នំពេញ បានប្រកាសផ្តល់ថវិកាចំនួន ២,៥ លានដុល្លារសហរដ្ឋអាមេរិក ដែលជាវិភាគទានរបស់រាជរដ្ឋាភិបាលជប៉ុន ទៅឱ្យភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

ប្រទេសជប៉ុនគឺជាប្រទេសផ្តល់ជំនួយធំបំផុតរបស់តុលាការនេះ ដែលបានផ្តល់ថវិកាជាទឹកប្រាក់សរុប ៧៨,៧ លានដុល្លារសហរដ្ឋអាមេរិក (៦២,៦ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ១៦,១ លានដុល្លារសម្រាប់ភាគីជាតិ) ចាប់តាំងពីតុលាការនេះ ចាប់ផ្តើមដំណើរការក្នុងឆ្នាំ ២០០៦ មក។ ថវិកានេះមានចំនួនប្រហែល ៤៤% នៃថវិកាទាំងមូលរបស់ប្រទេសផ្តល់ជំនួយដល់អ.វ.ត.ក។

ប្រធានការិយាល័យរដ្ឋបាលស្តីទី ឯកឧត្តម ក្រាញ់ តូនី និងអនុប្រធានការិយាល័យរដ្ឋបាល លោក Knut Rosandhaug បានធ្វើសេចក្តីថ្លែងការណ៍រួមគ្នាមួយថា “តាងនាមឱ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលជប៉ុន ដែលបានផ្តល់ថវិកាចុងក្រោយនេះ។ ថវិកាទាំងនេះគឺជាសក្ខីកម្មឆ្លុះបញ្ចាំងនូវការបន្តការគាំទ្ររបស់ប្រទេសជប៉ុន ចំពោះកិច្ចដំណើរការនីតិវិធីដ៏សំខាន់របស់ អ.វ.ត.ក ដែលកំពុងតែដំណើរការសវនាការជំនុំជម្រះមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម”។

Original EN: 00879329-00879329

**ដើម្បីព័ត៌មានបន្ថែម សូមទាក់ទង៖**

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ 0២៣
ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ៨៦១ ៦៦៩ –
លេខភ្ជាប់បន្ត៖ ៦១៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh